01197390 F30/18

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jan-2016, 15:16
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber
Chambre de la Cour supreme

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រីម ប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Agniezska KLONOWIECKAMILART** |
| | **ចៅក្រម ម៉ុង មុនីចរិយា** |
| | **ចៅក្រម Florence Ndepele Mwachande MUMBA** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទឯកសារ៖** | **ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦** |
| **ភាសាដើម៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ** |

# សេចក្តីសម្រេចស្តីពីការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា ក្នុងអំឡុងពេលសវនាការលើបណ្តឹងសាទុក្ខកាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("**អង្គជំនុំជម្រះតុលាការកំពូល**" និង"**អ.វ.ត.ក**" នីមួយៗ) ចេញសេចក្តីសម្រេចរបស់ខ្លួន ដោះស្រាយលើបញ្ហាពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់សហមេធាវីការពារក្តី នួន ជា (មេធាវីការពារក្តី នួន ជា) និងការគោរពតាមក្របខ័ណ្ឌច្បាប់ជាធរមាន ក្នុងអំឡុងពេលនៃសវនាការលើបណ្តឹងសាទុក្ខចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងផលវិបាកនានា ដែលកើតចេញពីការរំលោភជាសក្តានុពលលើក្របខ័ណ្ឌច្បាប់នេះ។

## ក. សាវតារ

2. អង្គជំនុំជម្រះតុលាការកំពូលចេញដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសទុក្ខ ក្នុងសំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សម្រាប់ថ្ងៃទី ១៧ ដល់ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ("សវនាការបណ្តឹងសាទុក្ខ")[1]។

3. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដែលជាថ្ងៃទីមួយនៃសវនាការបណ្តឹងសាទុក្ខ សហមេធាវីអន្តរជាតិការពារក្តីរបស់ នួន ជា លោក Victor KOPPE ("សហមេធាវីអន្តរជាតិ") ពុំបានបង្ហាញខ្លួននៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលឡើយ។ សហមេធាវីជាតិការពារក្តី នួន ជា លោក សុន អរុណ ("សហមេធាវីជាតិ") មានវត្តមាន[2]។

4. នៅពេលចាប់ផ្តើមសវនាការបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកសំណើរបស់ នួន ជា សុំធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់ខ្លួន[3]។ នៅក្នុងអំឡុងពេលនៃការថ្លែងនោះ នួន ជា បានប្រកាសក្នុង*ចំណោមនោះ*ថា ក្រោយពីបានពិភាក្សាជាមួយគាត់រួចមក សហមេធាវីអន្តរជាតិការពារក្តីរបស់គាត់នឹងពុំចូលរួមនៅក្នុងសវនាការនេះទេ[4]។ បន្ទាប់មក គាត់បានណែនាំសហមេធាវីជាតិការពារក្តីរបស់គាត់ "មិនឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះបន្តទៀត និងមិនត្រូវឆ្លើយតបទៅនឹងសំណួររបស់

---

[1] ដីកាកំណត់កាលវិភាគស្តាពរសម្រាប់សវនាការបណ្តឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវដោះស្រាយ ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/4។ ដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារ F30។

[2] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១។

[3] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ២ និង ៦។

[4] ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៤។

ចៅក្រម ឬភាគីដទៃឡើយ"[5]។ ទោះជាយ៉ាងណាក្តី នួន ជា បានបញ្ជាក់ថា គាត់"រក្សាទុកបណ្តឹងសាទុក្ខ [របស់គាត់]វិញ"ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចលើរូបគាត់នៅក្នុងសំណុំរឿង ០០២/០១[6]។

5. ជាការឆ្លើយតបទៅនឹងការប្រកាសរបស់សហមេធាវីជាតិថា គាត់ នឹងចាកចេញពីបន្ទប់សវនាការក្នុងពេលបន្តិចទៀតនោះ ដោយធ្វើទៅតាមការណែនាំរបស់កូនក្តីរបស់គាត់ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា បើទោះជាមានការណែនាំរបស់ នួន ជា យ៉ាងណាក៏ដោយ សហមេធាវីជាតិ គឺស្ថិតក្រោមកាតព្វកិច្ចត្រូវតែនៅក្នុងបន្ទប់សវនាការដើម្បីធានាបានថា កូនក្តីរបស់ខ្លួន ត្រូវបានការពារស្របច្បាប់នៅពេលសវនាការបណ្តឹងសាទុក្ខ ស្របតាមលក្ខខណ្ឌតម្រូវនៃក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ[7]។ សហមេធាវីជាតិបានជំទាស់ថា គាត់ត្រូវតែគោរព"ច្បាប់" និង"គោរពអង្គសវនាការ" ប៉ុន្តែបើកាលណាមិនស្តាប់បង្គាប់បញ្ជា និងការណែនាំកូនក្តីទេ កូនក្តីគេនឹងទាត់គាត់ចោលដូចគ្នា[8]។ អង្គជំនុំជម្រះតុលាការកំពូលបានរំលឹកម្តងទៀតអំពីកាតព្វកិច្ចរបស់សហមេធាវីជាតិ ដែលត្រូវតែនៅក្នុងបន្ទប់សវនាការ និងបានព្រមានថា ប្រសិនបើគាត់ចាកចេញពីបន្ទប់សវនាការ គាត់នឹងអាចត្រូវបានចាត់ទុកថា"ប្រមាថតុលាការ" និងយល់ឃើញថា សកម្មភាពរបស់គាត់ ទំនងជា"យុទ្ធវិធីក្នុងបំណងរំខានកិច្ចដំណើរការនីតិវិធី"[9]។ សហមេធាវីជាតិបានឆ្លើយតបថា ស្របតាមមាត្រា ៥៨ នៃលក្ខន្តិកៈរបស់មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា") គាត់មិនត្រឹមតែត្រូវ"គោរពអង្គសវនាការ"ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគោរពតាមសេចក្តីណែនាំរបស់កូនក្តីគាត់ផងដែរ[10]។ បន្ទាប់ពីបានស្តាប់ការលើកឡើងរបស់ភាគីដទៃទៀតលើបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការបញ្ជាក់ម្តងទៀតថា បើទោះបីជាសហមេធាវីជាតិមានសិទ្ធិក្នុងការមិនធ្វើអំណះអំណាងផ្ទាល់មាត់ ឬមិនឆ្លើយតបទៅនឹងសំណួរក្នុងពេលសវនាការបណ្តឹងសាទុក្ខក៏ដោយ ក៏សហមេធាវីជាតិ ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការ[11]។

---

[5] *ដូចយោងខាងលើ*។

[6] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៤។

[7] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៥ (ជួរទី ៨ ដល់ ១១), ១៥(ជួរទី ២៥) ដល់ ទំព័រ ១៦ (ជួរទី ៤), ១៦ (ជួរទី ១៤ ដល់ ជួរទី ១៩)។

[8] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៦។

[9] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៦ (ជួរទី ១៤ ដល់ ១៩)។

[10] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ១៦ ដល់ ១៧។

[11] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ២១ (ជួរទី ២៤) ដល់ទំព័រ ២២ (ជួរទី ៦)។

6. នៅពេលសវនាការបណ្តឹងសាទុក្ខ បានបន្តទៀតក្រោយពីការសម្រាករបស់តុលាការនាពេលព្រឹកនោះ សហមេធាវីជាតិ ពុំឃើញមានវត្តមាននៅក្នុងបន្ទប់សវនាការទៀតឡើយ[12]។ បន្ទាប់ពីបានស្នើឱ្យភាគីធ្វើសារណាទាក់ទងនឹងផលវិបាក ដែលប៉ះពាល់រយៈពេលវែងនៃការអវត្តមានរបស់សហមេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលបានផ្អាកសវនាការ ដើម្បីពិភាក្សាសម្រេចលើការរៀបចំកិច្ចដំណើរការនីតិវិធីបន្ថែមទៀត។

7. ដោយសារតែសហមេធាវីជាតិបានចាកចេញពីបន្ទប់សវនាការ ដែលជាការរំលោភលើការបង្គាប់យ៉ាងច្បាស់របស់តុលាការ និងដោយខ្វះការការពារក្តីស្របច្បាប់សម្រាប់ នួន ជា បូករួមជាមួយនឹងចេតនាច្បាស់លាស់ក្នុងការរក្សាជំហរបែបនេះ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ នួន ជា និងបានផ្អាកសវនាការបណ្តឹងសាទុក្ខ ដោយបានបញ្ជាក់ថា "ការប្រព្រឹត្តរបស់សហមេធាវីជាតិ និងអន្តរជាតិការពារក្តី នួន ជា ត្រូវបានចាត់ទុកថាជា កំហុសវិជ្ជាជីវៈ ដែលអាចនាំទៅដល់ការដាក់ទណ្ឌកម្មខាងវិន័យ" និងថា សេចក្តីសម្រេចពាក់ព័ន្ធបញ្ហានេះ នឹងត្រូវចេញតាមពេលវេលាសមស្រប[13] ។ សហមេធាវីជាតិ មានវត្តមាននៅក្នុងបន្ទប់សវនាការនៃបណ្តឹងសាទុក្ខក្នុងពេលរសៀល នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានធ្វើការប្រកាសសេចក្តីសម្រេចរបស់ខ្លួន។

8. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ សហមេធាវីជាតិ បានដាក់ឯកសារក្នុងគោលបំណងលើកឡើងនូវហេតុផល និងក្របខ័ណ្ឌច្បាប់សម្រាប់ការប្រព្រឹត្តរបស់គាត់ក្នុងពេលសវនាការបណ្តឹងសាទុក្ខ ("សារណារបស់សហមេធាវីជាតិ")[14]។ គាត់បានរំលឹកពីមាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជានិងសេចក្តីសម្រេចពីដំបូងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("សេចក្តីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា" និង"គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា" នីមួយៗ) យោងតាមមាត្រានេះ គាត់បានជំទាស់ថា មេធាវីត្រូវកំណត់តាម"សតិសម្បជញ្ញៈរបស់ខ្លួន" និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីជាប្រយោជន៍អតិថិជន និងដូច្នេះហើយ វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈ "ឯករាជ្យ និងសេរី ដែលចូលរួមបម្រើវិស័យយុត្តិធម៌ [...] ស្របតាមវិធានស្តីពីវិជ្ជាជីវៈរបស់ខ្លួន និងបទ

---

[12] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ២៥ ដល់ ២៦។

[13] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ៣១។

[14] ការឆ្លើយតបរបស់ លោក សុន អរុណទៅនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងព្រឹត្តិការណ៍នៃថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/13។

01197395



ប្បញ្ញត្តិជាធរមាន” និងជា“ជំនួយការយុត្តិធម៌សង្គម មិនមែនជាជំនួយការរបស់តុលាការទេ”[15]។ សហមេធាវីជាតិបានទទួលស្គាល់ថា គាត់ត្រូវតែ“គោរពការបង្គាប់របស់តុលាការ” ប៉ុន្តែបានអះអាងថា ការណែនាំរបស់កូនក្តីគាត់ គឺពុំមែន“ផ្ទុយនឹងច្បាប់ សតិសម្បជញ្ញៈ[របស់គាត់] ឬក្រមសីលធម៌ឡើយ” ហើយថា ជាលទ្ធផល គាត់ត្រូវបានចងកាតព្វកិច្ចឱ្យគោរពតាមទាំងអស់នេះ[16]។ គាត់កត់សម្គាល់ឃើញថា គាត់ត្រឡប់មកចូលក្នុងបន្ទប់សវនាការនៃបណ្តឹងសាទុក្ខវិញនៅពេលរសៀល ហើយគាត់មានការសោកស្តាយដែលថា “អង្គជំនុំជម្រះមិនបានចាប់អារម្មណ៍នឹងវត្តមាន[របស់គាត់] ហើយមិនបានផ្តល់ឱកាសដល់[គាត់] ដើម្បីនិយាយបើទោះបីជា [គាត់] បានស្នើក៏ដោយ”[17]។ នៅចុងបញ្ចប់ គាត់បានបញ្ជាក់ជំហររបស់គាត់ថា តាមការបង្គំរបស់អង្គជំនុំជម្រះ គាត់នឹងទៅអង្គុយនៅក្នុងបន្ទប់សវនាការនៃបណ្តឹងសាទុក្ខនៅក្នុងពេលខាងមុខក្នុងសំណុំរឿង ០០២/០១ តែគាត់នឹងបន្តគោរពតាមការណែនាំរបស់កូនក្តីគាត់ មិនឱ្យឆ្លើយតបនឹងសំណួររបស់ចៅក្រម និងគ្រប់ភាគី[18]។

9. នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ សហមេធាវីអន្តរជាតិ បន្ទាប់ពីការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល[19]បានដាក់ឯកសារក្នុងគោលបំណងបកស្រាយអំពីការអវត្តមានរបស់គាត់នៅក្នុងសវនាការបណ្តឹងសាទុក្ខ (“សារណារបស់សហមេធាវីអន្តរជាតិ”)[20]។ គាត់បានអះអាងថា កូនក្តីរបស់គាត់ “បានបញ្ជាក់នៅពេលសវនាការនោះរួចហើយថា កូនក្តីរបស់គាត់ បានណែនាំ[គាត់] មិនឱ្យមានវត្តមាននៅក្នុងពេលសវនាការនោះ” ដោយសារតែ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើសំណើរបស់ នួន ជា សុំដាក់ភស្តុតាងបន្ថែម ទើបបានធ្វើឱ្យ“លទ្ធផលនៃបណ្តឹងសាទុក្ខនេះ [...] ពុំជាប់ពាក់ព័ន្ធ”ទៅនឹង នួន

[15] សារណារបស់សហមេធាវីជាតិ កថាខណ្ឌ ៤ (ដកស្រង់លិខិតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទៅកាន់ប្រធានអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់មេធាវី គង់ សំអុន នៅក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥ ឯកសារលេខ E330/1/1 កថាខណ្ឌ ១ ក្នុងផ្នែក“គ. អំពីសំអាងហេតុ”)។

[16] សារណារបស់សហមេធាវីជាតិ កថាខណ្ឌ ៧។

[17] សារណារបស់សហមេធាវីជាតិ កថាខណ្ឌ ៨។

[18] សារណារបស់សហមេធាវីជាតិ កថាខណ្ឌ ៩។

[19] សេចក្តីសម្រេចស្នើឱ្យលោក Victor KOPPE ដាក់សារណាទាក់ទងទៅនឹងការខកខានរបស់ខ្លួនក្នុងការចូលរួមសវនាការបណ្តឹងសាទុក្ខ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/14 (“ការឆ្លើយតបរបស់សហមេធាវីអន្តរជាតិ”)។

[20] ការឆ្លើយតបរបស់ Victor KOPPE ទៅនឹងការស្នើរបស់អង្គជំនុំជម្រះតុលាការកំពូលសុំការបកស្រាយអំពីការអវត្តមានមិនបានចូលរួមសវនាការបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/14/1។

ជា[21]។ មេធាវីបានរំលឹកពីចេតនាផងដែរក្នុងការដកខ្លួនចេញពីសហមេធាវីអន្តរជាតិការពារក្តី នួន ជា ប៉ុន្តែ បានលើកឡើងថា បើទោះបីជា អ.វ.ត.ក "ពិតណាស់ គឺជា និងជានិច្ចកាលនឹងជាការកំប្លុកកំប្លែងទាំងស្រុង" ក៏គាត់នឹងពុំធ្វើដូច្នោះឡើយ[22]។

## ខ.ច្បាប់ជាធរមាន

### ១. កាតព្វកិច្ចរបស់មេធាវី ក្នុងការធានាបាននូវការការពារស្របច្បាប់ដល់ជនជាប់ចោទនៅក្នុងរឿងក្តីពាក់ព័ន្ធនឹងបទឧក្រិដ្ឋ

10. យោងតាមមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជំនួយពីមេធាវីត្រូវតែមានដាច់ខាត នៅក្នុងករណី*ក្នុងចំណោមនោះ* កិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទឧក្រិដ្ឋ។ ដោយស្របតាមបទប្បញ្ញត្តិនេះ វិធាន ៨១(៧) នៃវិធានផ្ទៃក្នុង ចែងថា "នៅពេលមេធាវីរបស់ជនជាប់ចោទ មិនមានវត្តមានក្នុងអំឡុងពេលសវនាការដោយគ្មានការបញ្ជាក់អំពីមូលហេតុ អង្គជំនុំជម្រះសាលាដំបូង អាចពន្យារពេលសវនាការ ឬបើសិនជនជាប់ចោទស្នើសុំជំនួយមេធាវី អាចស្នើសុំឱ្យអង្គភាពគាំពារការការពារក្តីចាត់តាំងមេធាវីជាបណ្តោះអាសន្នសម្រាប់ជនជាប់ចោទនោះបាន"។

11. ការអនុវត្តតាមប្រកបដោយអត្ថន័យលើមាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាតម្រូវថា មេធាវីការពារក្តីជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក ត្រូវតែមានវត្តមាននៅក្នុងបន្ទប់សវនាការពេញមួយអំឡុងពេលនៃសវនាការ ដោយត្រូវឯករាជ្យពីការណែនាំណាមួយរបស់ជនជាប់ចោទដែលផ្ទុយពីនេះ[23]។

### ១. ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់មេធាវី

12. វិធាន ២២(៤) នៃវិធានផ្ទៃក្នុងបញ្ជាក់អំពីក្របខ័ណ្ឌច្បាប់សម្រាប់ការប្រព្រឹត្តរបស់មេធាវីដែលត្រូវអនុវត្តចំពោះមុខ អ.វ.ត.ក ដូចខាងក្រោមថា៖

> ក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង[24] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់ អ.វ.ត.ក ក៏ដូច

[21] សារណារបស់សហមេធាវីអន្តរជាតិ កថាខណ្ឌ ៧ និង ៨។

[22] សារណារបស់សហមេធាវីអន្តរជាតិ កថាខណ្ឌ ៣, ៥, ៦, និង ១០។

[23] *សូមមើល* ប្រតិចារឹកថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F1/4.1 ទំព័រ ៣១។ អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះតុលាការកំពូលចំណងជើងថា "ការអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលឱ្យចាត់តាំងមេធាវីត្រៀមបម្រុងសម្រាប់ការពារក្តី នួន ជា" ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ F30/15 ទំព័រ ៣។

ជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និងបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់។ ពួកគេមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវ។

13. កិច្ចព្រមព្រៀងចែងប្រហាក់ប្រហែលគ្នានេះនៅក្នុងមាត្រា ២១(៣) ថា៖

មេធាវីណាដែលមានសញ្ជាតិខ្មែរ ឬមិនមែនខ្មែរ ដែលត្រូវបានជួលឬចាត់តាំងឱ្យធ្វើការជាមួយជនសង្ស័យ ឬជនជាប់ចោទ ក្នុងការការពារកូនក្តីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា បទដ្ឋាន និងក្រមសីលធម៌នៃវិជ្ជាជីវៈស្របច្បាប់ដែលគេទទួលស្គាល់។

14. មាត្រា ៣៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា បានចែងនូវសច្ចាប្រណិធានដែលមេធាវីត្រូវធ្វើនៅមុខ“សាលាឧទ្ធរណ៍”ដូចតទៅថា៖

“ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈរបស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសម្បជញ្ញៈ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា”។

វិធាននៃវិជ្ជាជីវៈមេធាវីត្រូវបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់គណៈមេធាវី។ វិធាននេះធានាការគោរពដោយមេធាវីនូវគោលការណ៍ទាំងឡាយនៃសច្ចាប្រណិធានរបស់ខ្លួន ដូចបានបញ្ជាក់នៅក្នុងវិធានផ្ទៃក្នុងរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[25]។

15. មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជាចែងនៅក្នុងផ្នែកពាក់ព័ន្ធថា “មេធាវី កំណត់សតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផងនូវអ្វីដែលខ្លួនត្រូវលើកឡើង ដើម្បីការពារប្រយោជន៍របស់អតិថិជនដែលខ្លួនទទួលបន្ទុក” និងបានចែងបន្ថែមទៀតថា ជនណាប្រព្រឹត្តល្មើសនឹងមាត្រា ៥៨ ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ[26]។

---

[24] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការកាត់ទោសតាមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើយនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ (ចូលជាធរមាននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥) (“កិច្ចព្រមព្រៀង”)(ជើងទំព័រច្បាប់ពុំមែនច្បាប់ដើម)។

[25] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា មាត្រា ៥៦។

[26] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា មាត្រា ៧៨។

16. ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា("ក្រមសីលធម៌មេធាវី")[27] រៀបរាប់នូវគោលការណ៍គ្រឹះក្នុងមាត្រា ៣ ថា៖

> នៅគ្រប់កាលៈទេសៈទាំងអស់ មេធាវីត្រូវគោរពពាក្យសម្បថរបស់ខ្លួន និងត្រូវគោរពគោលការណ៍សម្បជញ្ញៈ មនុស្សធម៌ សេចក្ដីថ្លៃថ្នូរនៃវិជ្ជាជីវៈ។ មេធាវី មិនត្រូវចូលរួមសកម្មភាពដែលមានលក្ខណៈផ្ទុយនឹងច្បាប់ វិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។

17. ក្រមសីលធម៌មេធាវី បានបញ្ជាក់បន្ថែមទៀតថា មេធាវី ត្រូវ (១) ប្រកាន់ឱ្យបានខ្ជាប់នូវឯករាជ្យភាព និងសេចក្ដីថ្លៃថ្នូរក្នុងវិជ្ជាជីវៈ ចំពោះមុខតុលាការ[28] (២) គោរពតាមវិធានស្ដីពីនីតិវិធី និងបទបញ្ជារបស់តុលាការ[29] (៣) ត្រូវរួចផុតពីការចោទប្រកាន់ ក្នុងបទព្រហ្មទណ្ឌនិងការទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះសេចក្ដីថ្លែងការណ៍ ឬសារណា ទោះធ្វើជាលាយលក្ខណ៍អក្សរក្ដី ជាផ្ទាល់មាត់ក្ដី ក្នុងបំណងសុចរិតដើម្បីការពារនៅចំពោះមុខតុលាការ សាលាជម្រះក្ដី ឬអាជ្ញាធរផ្សេងៗទៀត[30] (៤) ទាមទារ និងស្វះស្វែងធ្វើឱ្យមានការជំនុំជម្រះក្ដីដោយយុត្តិធម៌ គោរពតាមច្បាប់ និងនីតិវិធីដ៏ត្រឹមត្រូវឱ្យកើតមានយ៉ាងពិតប្រាកដ[31] និង (៥) មិនត្រូវបង្កឱ្យមានការពន្យារនីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬមូលហេតុមិនសមស្រប ដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ[32]។

18. ទំនាក់ទំនងរវាងកាតព្វកិច្ចរបស់មេធាវីដែលត្រូវគោរពតាមសម្បជញ្ញៈរបស់ខ្លួន និងសេចក្ដីណែនាំរបស់កូនក្ដី និងកាតព្វកិច្ចត្រូវគោរពតាមបទបញ្ជានៃលក្ខន្តិកៈ និងការបង្គាប់របស់តុលាការ ត្រូវបានវិភាគនៅក្នុងសេចក្ដីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបរាប់ដូចខាងក្រោមនៅក្នុងផ្នែកដែលពាក់ព័ន្ធថា៖

> វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌ មានន័យថា នៅក្នុងការប្រកបវិជ្ជាជីវៈ មេធាវីម្នាក់ៗមានឯករាជភាពក្នុងការងារបច្ចេកទេសរបស់ខ្លួនស្របតាមវិធានវិជ្ជាជីវៈ និងបទប្បញ្ញត្តិជាធរមាននៅក្នុងការផ្ដល់សេវាកម្មច្បាប់ជូនអតិថិជន ដោយមិនស្ថិតក្រោម

---

[27] អនុម័តដោយក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២។

[28] ក្រមសីលធម៌មេធាវី មាត្រា ៣៧។

[29] *ដូចយោងខាងលើ*។

[30] *ដូចយោងខាងលើ*។

[31] ក្រមសីលធម៌មេធាវី មាត្រា ៣៨។

[32] ក្រមសីលធម៌មេធាវី មាត្រា ៣៩។

សម្ពាធ ឬការជ្រៀតជ្រែកពីបុគ្គលណា ឬពីស្ថាប័នណាមួយឡើយ។ ដើម្បីការពារប្រយោជន៍អតិថិជន មេធាវីត្រូវការឱ្យមានការពិគ្រោះយោបល់ និងទទួលស្ដាប់ការណែនាំពីអតិថិជនដែលជាម្ចាស់ផលប្រយោជន៍។ មេធាវីជាជំនួយការយុត្តិធម៌របស់សង្គម មិនមែនជាជំនួយការរបស់តុលាការទេ។ ទោះបីជាមេធាវីបំពេញការងារដើម្បីជាប្រយោជន៍របស់អតិថិជនក៏ដោយ ក៏មេធាវីមិនអាចធ្វើកិច្ចការណាដែលផ្ទុយនឹងច្បាប់ ឬមានចេតនាពន្យារនីតិវិធីដោយគ្មានហេតុផលច្បាស់លាស់ទេ[33]។

19. មេធាវីដែលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ត្រូវគោរពតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដូចបានបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចលើសំណើសុំចាត់ការតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង")[34] និងមានចែងយ៉ាងច្បាស់លាស់នៅក្នុងមាត្រា ៣៥(៥)។ វិធាន ៣៥(១) នៃវិធានផ្ទៃក្នុង បានរៀបរាប់យ៉ាងលម្អិតនូវការប្រព្រឹត្តជាច្រើនដែល ប្រសិនបើបានប្រព្រឹត្តឡើងដោយដឹង និងដោយចេតនា អាចមានគុណវុឌ្ឍិស្មើនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។ សេចក្ដីសម្រេចលើសំណើសុំចាត់ការតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងអះអាងថា វិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ប្រមើលទុកជាមុននូវបទព្រហ្មទណ្ឌ និងបទល្មើសផ្នែករដ្ឋបាលផងដែរ ដែលបទព្រហ្មទណ្ឌត្រូវស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌ ហើយបទល្មើសផ្នែករដ្ឋបាល ត្រូវបានកំណត់អត្តសញ្ញាណដោយ"ចៅក្រម និងអង្គជំនុំជម្រះនៃ អ.វ.ត.ក"[35]។ ជាការកត់សម្គាល់យ៉ាងពិសេសនៅក្នុង កាលៈទេសៈបច្ចុប្បន្នឃើញថា មួយផ្នែក មាត្រា ៥២៣ ក្នុងប្រយោគទីពីរនៃក្រមព្រហ្មទណ្ឌកម្ពុជា បានភ្ជាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទៅនឹង"អំពើដែលមិនអនុវត្តសេចក្ដីសម្រេចរបស់តុលាការ" ហើយ មួយផ្នែកទៀត វិធាន ៣៥(១)(ខ) នៃវិធានផ្ទៃក្នុងអាចដាក់ទណ្ឌកម្មជនណាម្នាក់ ដែល "ដោយគ្មានមូលហេតុសមស្របមិនគោរពតាមសេចក្ដីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្ដី" នៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចរួចរាល់ហើយថា "ការប្រព្រឹត្តដទៃទៀតដែលត្រូវបានហាមឃាត់ [តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង] រួមមានការបង្កការរំខាននៅក្នុងបន្ទប់សវនាការ" និង "ការប៉ះពាល់ដល់ ដំណើរការផ្នែកសម្ភាររបស់តុលាការ"[36]។

---

[33] សេចក្ដីសម្រេចរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា កថាខណ្ឌ ១ ក្នុងផ្នែក "គ.អំពីសំអាងហេតុ"។

[34] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ កថាខណ្ឌ ៣៦។

[35] សេចក្ដីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៣២ ដល់ ៣៣។

[36] សេចក្ដីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៣៦។

20. មាត្រា ៣៨ នៃវិធានផ្ទៃក្នុង ចែងជាក់លាក់នូវដំណោះស្រាយចំពោះកំហុសវិជ្ជាជីវៈរបស់មេធាវី និងអាចអនុវត្តបានដោយឯករាជ្យ ឬដោយរួមជាមួយនឹងវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ បើផ្អែកតាមការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ កំហុសវិជ្ជាជីវៈរបស់មេធាវី ត្រូវបានកំណត់និយមន័យថាជាការប្រព្រឹត្តដែល"ត្រូវបានចាត់ទុកជាបទល្មើស ឬជាការប្រមាថ ដែលរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ដែលស្មើនឹងការរំលោភបំពានទៅលើនីតិវិធី ឬផ្ទុយទៅនឹងមាត្រា ២១ (៣) នៃកិច្ចព្រមព្រៀង"[37]។ នៅ អ.វ.ត.ក ការប្រព្រឹត្តដែលត្រូវបានចាត់ទុកក្រោមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង រួមបញ្ចូលទាំងការបង្ហាញឯកសារសម្ងាត់ជាសធារណៈ:[38] ការបដិសេធដោយពុំបានជូនដំណឹងជាមុនក្នុងការមិនបន្តការចូលរួមនៅក្នុងសវនាការដោយសារការចោទប្រកាន់ថាមានវិការៈផ្នែកនីតិវិធី[39] ការប្រើប្រាស់នូវភាសាប្រមាថមាក់ងាយ ដល់ចៅក្រម[40] ការបន្តសួរសំណួរឥតពាក់ព័ន្ធ ឬឥតសមស្របទៅលើសាក្សីដោយពុំយកចិត្តទុកដាក់លើការបង្គាប់ និងការព្រមានច្រើនដងពីតុលាការ[41] ការអវត្តមានដោយឥតរំពឹងទុកក្នុងពេលសវនាការដែលបាន ធ្វើឱ្យមានការផ្អាកសវនាការ ដោយសារតែការពុំបានចូលរួមប្រកបដោយមានអត្ថន័យនៅក្នុងសវនាការ ដែលត្រូវបានកំណត់កាលបរិច្ឆេទឡើងវិញ[42] និងអាកប្បកិរិយាដែលជាបទល្មើស ប្រមាថបំពាន ឬឥតក្រមសីលធម៌ជាដើម[43]។

## ៣. ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធទៅនឹងនីតិវិធី និងការដាក់ទណ្ឌកម្មក្នុងករណីដែលមានកំហុសវិជ្ជាជីវៈរបស់មេធាវី

[37] វិធាន ៣៨(១) នៃវិធានផ្ទៃក្នុង។

[38] ដីកាសម្រេចស្តីពីការរំលោភបំពាលើការសម្ងាត់នៃកិច្ចស៊ើបសួរ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ D138 កថាខណ្ឌ ១៩ ដល់ ២០។ *សូមមើលផងដែរ* សេចក្តីសម្រេចស្តីពីកំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តី នួន ជា ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E214 ("សេចក្តីសម្រេចរបស់ អ.ជ.ស.ដ") កថាខណ្ឌ ៧។

[39] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៨ ឯកសារលេខ C26/I/25 ("សេចក្តីសម្រេចដំបូងរបស់ អ.ប.ជ") កថាខណ្ឌ ៤, ១១ និង ១៥។

[40] ការព្រមានដល់សហមេធាវីអន្តរជាតិ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ឯកសារលេខ C26/5/22 ("សេចក្តីសម្រេចទីពីររបស់ អ.ប.ជ") កថាខណ្ឌ ៣០។ ឧបសម្ព័ន្ធទីពីរ-ការបន្តប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់មេធាវីដែលត្រូវបានទទួលស្គាល់ដោយគណៈមេធាវី-បញ្ហារបស់មេធាវី Andrew IANUZZI, Docket No: 2012.1596 ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៣ ឯកសារលេខ E214/5។

[41] ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/153.1, ទំព័រ ៣៤ ដល់ ៣៥, ៣៨ ដល់ ៣៩, ៤១ ដល់៤៥។

[42] សេចក្តីសម្រេចទីពីររបស់ អ.ប.ជ កថាខណ្ឌ ៣១។

[43] *សូមមើល*សេចក្តីសម្រេចរបស់ អ.ប.ជ។

21. លទ្ធភាពផ្នែកនីតិវិធីដែល អ.វ.ត.ក មានដើម្បីដោះស្រាយកំហុសវិជ្ជាជីវៈរបស់មេធាវី គឺអាស្រ័យទៅលើបញ្ហាថាតើ ការប្រព្រឹត្តនោះ ត្រូវបានចាត់ទុកថា ស្ថិតក្រោមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង ដែលត្រូវបានសម្របសម្រួលយ៉ាងពិសេសដើម្បីដោះស្រាយកំហុសវិជ្ជាជីវៈរបស់មេធាវី ដែរ ឬយ៉ាងណា ឬក៏ស្ថិតក្រោមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុង ដែលជាប់ពាក់ព័ន្ធទៅនឹងការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការនោះ។

22. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ការចាត់វិធានការតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង អាចត្រូវធ្វើឡើង ប្រសិនបើមានមូលហេតុគួរឱ្យជឿបានថា បុគ្គលណាម្នាក់ បានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ[44] និងថា "នីតិវិធីសម្រាប់បង្ហាញការទទួលខុសត្រូវ ថាតើជាបទព្រហ្មទណ្ឌ ឬបទល្មើសផ្នែករដ្ឋបាល គប្បីស្របជាមួយនឹងលក្ខខណ្ឌតម្រូវមូលដ្ឋានស្តីពីភាពត្រឹមត្រូវ"[45]។ នីតិវិធីសាមញ្ញសម្រាប់កំណត់ការទទួលខុសត្រូវដែលមានចែងក្នុងវិធាន ៣៥(២)(ខ)នៃវិធានផ្ទៃក្នុង មានលក្ខណៈសមស្របយ៉ាងពិសេសសម្រាប់អំពើដែល"ដឹងជាសាធារណៈដោយសារតែចរិតលក្ខណៈរបស់អំពើនេះ ... អំពើដែលត្រូវបានថតចូលក្នុងវីដេអូរបស់តុលាការ"[46]។ ជនទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចដំណើការនីតិវិធីរបស់វិធាន ៣៥ នៃវិធានផ្ទៃក្នុង ត្រូវទទួលបានជំនួយផ្នែកច្បាប់[47]។ រាល់សេចក្តីសម្រេចក្រោមវិធាននេះ អាចប្តឹងឧទ្ធរណ៍បាន[48]។

23. វិធាន ៣៥ នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិអំណាចដល់ អ.វ.ត.ក ក្នុងការ "ដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច"នូវជនណាម្នាក់ដែលជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ។ អង្គជំនុំជម្រះតុលាការកំពូលបកស្រាយបទប្បញ្ញត្តិនេះថាជាការអនុញ្ញាតឱ្យមានការឆ្លើយតប"ដែលចាំបាច់ក្នុងការធានាបាននូវសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី" មិនថាជាការដាក់ ឬក៏មិនដាក់ទណ្ឌកម្មយ៉ាងណាក៏ដោយនោះទេ ក្នុងន័យដើម្បីបន្ថែមទៅលើការដាក់ទណ្ឌកម្មពីបទព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់កម្ពុជាទៅលើបទល្មើសណាមួយត្រូវបានប្រព្រឹត្តឡើង[49]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះរៀបរាប់ការដាក់ទណ្ឌកម្ម

---

[44] សេចក្តីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៣៩។

[45] សេចក្តីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៤២។

[46] សេចក្តីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៤១។

[47] វិធាន ៣៥(៣) នៃវិធានផ្ទៃក្នុង។

[48] វិធាន ៣៥(៦) នៃវិធានផ្ទៃក្នុង។

[49] សេចក្តីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងកថាខណ្ឌ ៤៤ ដល់ ៤៥។

ផ្នែករដ្ឋបាលយ៉ាងច្រើនដែលអាចមាន ដូចជា"ការព្រមាន" "ការជូនដំណឹងដល់អង្គភាពដាក់វិន័យ" "ការផ្សព្វផ្សាយលទ្ធផលនៃកិច្ចដំណើរការនីតិវិធីក្នុងសារព័ត៌មាន" និង"ការផាកពិន័យរដ្ឋបាលដោយមានកម្រិត"[50]។ ការដាក់ទណ្ឌកម្មទាំងអស់នេះ ត្រូវតែស្របជាមួយនឹងគោលការណ៍ស្ដីពីភាពចាំបាច់ និងគោលការណ៍សមាមាត្រ[51]។

24. វិធាន ៣៨ នៃវិធានផ្ទៃក្នុង ត្រូវបានតាក់តែងឡើងដើម្បីដោះស្រាយកំហុសវិជ្ជាជីវៈរបស់មេធាវី ដោយពុំគិតថា តើ កំហុសនេះមានគុណវុឌ្ឍិជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ដែរ ឬយ៉ាងណានោះឡើយ។ វិធាននេះផ្ដល់ជាដំណោះស្រាយងាយស្រួលជាង និងមានទម្រង់បែបទនៃនីតិវិធីខ្លីជាង វិធាន ៣៥ នៃវិធានផ្ទៃក្នុង និងពុំបានផ្ដល់ការការពារផ្នែកច្បាប់ ឬសិទ្ធិប្ដឹងឧទ្ធរណ៍ឡើយ។ ការរកឃើញថាមានកំហុសវិជ្ជាជីវៈ បន្ទាប់ពីមានការព្រមានម្ដង អាចឈានទៅដល់"ការដាក់ទណ្ឌកម្មនានា" "ការបដិសេធមិនឱ្យមេធាវីណាមួយចូលរួមសវនាការ" ឬបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅឱ្យអង្គភាពមានសមត្ថកិច្ចសមស្រប[52]។ ដោយសារតែវិសាលភាពជាក់ស្ដែងនៃ"ទណ្ឌកម្ម" តាមវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង ពុំទាន់ត្រូវបានកំណត់ច្បាស់លាស់នៅឡើយ ទើបធ្វើឱ្យមានការព្រមានជាញឹកញាប់ ដែលជាវិធានការទប់ស្កាត់ផង និងដាក់ទោសផងសម្រាប់កំហុសវិជ្ជាជីវៈ[53] ដែលមានករណីមួយនោះ បន្ទាប់ពីបានព្រមានច្រើនដង មេធាវីម្នាក់ ត្រូវបានបណ្ដេញចេញពីបន្ទប់សវនាការ[54]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា វិសាលភាពដែលអនុញ្ញាតសម្រាប់កំហុសវិជ្ជាជីវៈតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ក៏បានរួមបញ្ចូលផងដែរនូវការ*ស្ដីបន្ទោស*ជាផ្លូវការជាលក្ខណៈឯកជន ឬសាធារណៈ ដូចជា"ទម្រង់សមគួរមួយស្ដីពីវិន័យមេធាវី" ដែល "ប្រកាសអំពីការប្រព្រឹត្តរបស់មេធាវីថាពុំត្រឹមត្រូវ ប៉ុន្តែពុំបានកម្រិតលើសិទ្ធិរបស់

---

[50] សេចក្ដីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៤៤។

[51] *ដូចយោងខាងលើ*។

[52] វិធាន ៣៨(១) និង(២) នៃវិធានផ្ទៃក្នុង។

[53] *សូមមើលឧ.* សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខភ្លាម របស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីភាពត្រឹមត្រូវនៃការស៊ើបអង្កេតរបស់តុលាការ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E116/1/7 កថាខណ្ឌ ៣៧ និង ផ្នែកសម្រេចសេចក្ដី។ សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ទំព័រ ៨។ សេចក្ដីសម្រេចទីពីររបស់ អ.ប.ជ ទំព័រ ១០។ សេចក្ដីសម្រេចលើកទីមួយរបស់ អ.ប.ជ ទំព័រ ៤។

[54] ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ ឯកសារលេខ E1/153.1 ទំព័រ ៦៤ ដល់ ៦៥។

មេធាវីក្នុងការអនុវត្តច្បាប់ឡើយ”[55]។ គោលការណ៍គ្រឹះស្តីអំពីភាពត្រឹមត្រូវ កំណត់ថា ការដាក់ទណ្ឌកម្ម ដែលកើតចេញពីផលវិបាកធ្ងន់ធ្ងរ ដូចជាការបដិសេធយូរអង្វែង ឬជាអចិន្ត្រៃយ៍នូវសិទ្ធិរបស់មេធាវីក្នុងការចូលរួមសវនាការ ឬទណ្ឌកម្មជាប្រាក់កាស អាចធ្វើទៅបានតែក្នុងករណីដើម្បីធានាដល់ការគោរពតាមនីតិវិធី។ ទាក់ទងនឹងបញ្ហានេះ វិធានស្តីពីនីតិវិធីដែលបានរៀបរាប់នៅក្នុងវិធាន ៣៥ នៃវិធានផ្ទៃក្នុង អាចអនុវត្តតាមលក្ខណៈសទិសភាព[56]។

## គ. ការពិភាក្សា

25. ក្របខ័ណ្ឌច្បាប់ជាធរមានដែលបានរួមបញ្ចូលច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា និងក្រមសីលធម៌មេធាវីបានបញ្ជាក់យ៉ាងច្បាស់លាស់ថា មេធាវី បើទោះបីជាធ្វើទៅតាមសម្បជញ្ញៈ និងការណែនាំរបស់កូនក្តីខ្លួនក៏ដោយ ក៏ត្រូវតែគោរពច្បាប់ និងបទបញ្ញាជាធរមានដទៃទៀត រួមទាំងការបង្គាប់របស់តុលាការផងដែរ។

26. មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា ដែលសហមេធាវីជាតិបានសំអាងក្នុងការបង្ហាញថាការប្រព្រឹត្តរបស់ខ្លួននៅក្នុងសវនាការបណ្តឹងសាទុក្ខសមហេតុផលនោះ ចែងថា “ការយល់ព្រមពីអតិថិ

---

[55] វចនានុក្រមច្បាប់ (Black’s Law Dictionary) បោះពុម្ពលើកទី ៩ ដោយ Thomson Reuters ឆ្នាំ ២០០៩ ទំព័រ ១៤១៧។ *សូមមើលផងដែរ*ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា មាត្រា ៦៣។ តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន“ក្រមស្តីពីការរៀបចំសវនាការ សេចក្តីសម្រេច [re Yada Williams]” ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៥ (ការស្តីបន្ទោសជាសាធារណៈ និងការផាកពិន័យចំពោះការរំលោភកាតព្វកិច្ចរបស់មេធាវីដែលត្រូវតែអនុវត្តសមគួរ និងដោយគោរពចំពោះបុគ្គលទាំងអស់ រួមទាំងបុគ្គលិកតុលាការផងដែរ)។

[56] *សូមអាចដោយប្រៀបធៀបជាមួយនឹង*តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ូហ្វាន់ដា *រឿងក្តី Nshogoza ទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-2007-91-A, “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងទណ្ឌកម្ម” អង្គជំនុំជម្រះឧទ្ធរណ៍ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ២៩ (ដោយពុំរាប់បញ្ចូលនូវលទ្ធភាពដែលថា វិសាលភាពនៃទណ្ឌកម្មដែលអាចត្រូវបានអនុវត្តតាមវិធាន ៤៦ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង (“RPE”)–ពាក្យពេចន៍នៃវិធាននេះ មានលក្ខណៈដូចគ្នាខ្លាំងទៅនឹងវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង–រួមមានទណ្ឌកម្មខាងប្រាក់កាស ពីព្រោះ ទណ្ឌកម្មប្រភេទនេះពុំត្រូវបានចែងច្បាស់លាស់នៅទីនោះទេ ដែលផ្ទុយនឹងបទប្បញ្ញត្តិរបស់RPE)។ នៅ អ.វ.ត.ក អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចរួចរាល់ហើយថា ពាក្យពេចន៍វិធាន ៣៥(១) នៃវិធានផ្ទៃក្នុងចែងថា (“អ.វ.ត.ក អាចដាក់ទណ្ឌកម្ម [...]”)–ប្រហាក់ប្រហែលគ្នាទៅនឹងវិធាន ៣៨(១) នៃវិធានផ្ទៃក្នុងត្រង់ថា វិធាននេះ ពុំបានចែងជាក់លាក់អំពីសាលភាពនៃទណ្ឌកម្មដែលអាចធ្វើបាន–អនុញ្ញាតឱ្យធ្វើការផាកពិន័យមានកម្រិតផ្នែករដ្ឋបាល (សេចក្តីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៤៤)។ អាស្រ័យហេតុនេះ អំណះអំណាងជាប្រព័ន្ធនិងពាក់ព័ន្ធពាក់ពេចន៍ ដែលអង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការ ICTR បានសំអាងទៅលើក្នុង *រឿងក្តី Nshogoza* គឺពុំសមស្របនៅក្នុងបរិបទនៃ អ.វ.ក.ត ឡើយ។

ជន" គប្បីជាការតម្រែតម្រង់មេធាវីក្នុងការធ្វើការសម្រេចលើ"បញ្ហាអ្វីខ្លះដែលត្រូវលើកឡើងដើម្បីការពារផលប្រយោជន៍អតិថិជន"។ ដោយសារហេតុនេះហើយទើប មេធាវី ស្ថិតក្រោមកាតព្វកិច្ចមិនត្រូវអនុវត្តផ្ទុយនឹងបំណងប្រាថ្នារបស់អតិថិជនដែលចង់បានតាមរូបភាពណាមួយ និងការអនុវត្តទៅតាមយុត្តិសាស្ត្រការការពារក្តី ដែលរួមបញ្ចូលពាក្យបណ្តឹងតាមផ្លូវច្បាប់ដែលត្រូវដាក់ទៅតុលាការ បញ្ហាដែលត្រូវលើកឡើងនៅចំពោះមុខចៅក្រម និងយុទ្ធវិធីដែលត្រូវប្រើក្នុងអំឡុងពេលសវនាការ។ ទោះជាយ៉ាងណាក្តី នៅគ្រប់កាលៈទេសៈទាំងអស់ មេធាវីពុំអាច"អនុវត្តផ្ទុយនឹងច្បាប់បានឡើយ" ដែលត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[57] ហើយសហមេធាវីជាតិ ក៏បានទទួលស្គាល់បទប្បញ្ញត្តិនេះផងដែរ[58]។ គ្មានការណែនាំរបស់អតិថិជនណា អាចបង្គាញការអនុវត្តផ្ទុយពីច្បាប់ ថាសមស្របឡើយ។ ផ្ទុយពីការយល់ឃើញពុំត្រឹមត្រូវដែលបានលើកឡើងនៅក្នុងសារណារបស់សហមេធាវីជាតិ មេធាវីត្រូវមានកាតព្វកិច្ចចំពោះតុលាការផង និងអតិថិជនរបស់ខ្លួនផង[59]។ ប៉ុន្តែ នៅពេលមានទំនាស់កើតឡើងរវាងការណែនាំ

---

[57] សេចក្តីសម្រេចរបស់គណៈមេធាវី កថាខណ្ឌ ១ ក្នុងផ្នែក "គ.អំពីសំអាងហេតុ"។ *សូមមើលផងដែរ*ក្រមសីលធម៌មេធាវី មាត្រា ៣៧។

[58] សារណារបស់សហមេធាវីជាតិ កថាខណ្ឌ ៧។

[59] *សូមមើលរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Barayagwiza*, សំណុំរឿងលេខ ICTR-97-19-T "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំដកខ្លួន" អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០០ កថាខណ្ឌ ២១ ដល់ ២២។ *សូមមើលផងដែរ រឿងក្តី Rondel ទល់នឹង Worsley* សភាជាន់ខ្ពស់របស់អង់គ្លេស (ឆ្នាំ ១៩៦៩) 1 AC 191, 227 (Lord Reid: "មន្ត្រីរបស់តុលាការដែលពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលតុលាការ[ដែលជាអ្នកអនុវត្តច្បាប់] ត្រូវចង់កាតព្វកិច្ចយ៉ាងសំខាន់ចំពោះតុលាការ ទបដ្ឋាននៃវិជ្ជាជីវៈរបស់ខ្លួន និងសាធារណជន ដែលអាច និងញឹកញាប់ឈានទៅរកការផ្ទុយទៅនឹងបំណងប្រាថ្នារបស់កូនក្តីខ្លួន ឬអ្វីដែលកូនក្តីគិតថា ជាផលប្រយោជន៍ផ្ទាល់ខ្លួននោះ") *ក្នុងរឿងក្តី re Griffiths*, តុលាការកំពូលរបស់សហរដ្ឋអាមេរិក (ឆ្នាំ ១៩៧៣) សំណុំរឿងលេខ 413 U.S. 717, 732 (មតិជំទាស់របស់ចៅក្រម Burger, C.J., "តួនាទីរបស់មេធាវី [...] រួមមានការបំពេញកាតព្វកិច្ចទីមួយដល់កូនក្តី។ ប៉ុន្តែថា កាតព្វកិច្ចនេះពុំដែលធ្លាប់ជាកាតព្វកិច្ចដាច់ខាត ឬដែលពុំអាចកែប្រែបាននោះឡើយ។ វាគឺជាការស្មោះត្រង់ទីមួយក្នុងការបម្រើផលប្រយោជន៍កូនក្តី ប៉ុន្តែជានិច្ចកាល ត្រូវតែស្ថិតក្រោមច្បាប់ ហើយមិនដែលចេញក្រៅពីរង្វង់ច្បាប់បានឡើយ")។ *In re Integration of Nebraska State Bar Association*, តុលាការកំពូលរបស់ Nebraska (ឆ្នាំ ១៩៣៧), សំណុំរឿងលេខ 275 NW 265, 268 ("មេធាវីចងកាតព្វកិច្ចចំពោះតុលាការ")។ *រឿងក្តី Giannarelli ទល់នឹង Wraith*, តុលាការជាន់ខ្ពស់របស់អូស្ត្រាលី (ឆ្នាំ ១៩៨៨), សំណុំរឿងលេខ 165 CLR 543, 556 (Mason CJ: "លក្ខណៈពិសេសនៃការទទួលខុសត្រូវរបស់មេធាវីគឺថា ចង់កាតព្វកិច្ចទៅនឹងតុលាការ ក៏ដូចជាទៅនឹងកូនក្តីរបស់ខ្លួនផងដែរ។ កាតព្វកិច្ចរបស់មេធាវីចំពោះកូនក្តី គឺពុំសូវសំខាន់ដូចកាតព្វកិច្ចចំពោះតុលាការឡើយ"។ "កាតព្វកិច្ចចំពោះតុលាការ គឺសំខាន់បំផុត [...] បើទោះបីជាកូនក្តីផ្តល់ការណែនាំផ្ទុយពីនេះក៏ដោយ")។

របស់អតិថិជន ជាមួយនឹងបទបញ្ញាជាធរមាន រួមមានការបង្គាប់របស់តុលាការ មេធាវីត្រូវតែអនុវត្តតាមការបង្គាប់របស់តុលាការ។

27. អង្គជំនុំជម្រះតុលាការកំពូល លើកយកវិធានទាំងនេះ ទៅអនុវត្តចំពោះការប្រព្រឹត្តរបស់សហមេធាវីជាតិ និងអន្តរជាតិ។

28. សហមេធាវីអន្តរជាតិ ពុំបានបង្ហាញខ្លួននៅពេលសវនាការបណ្តឹងសាទុក្ខ ដែលលទ្ធភាពក្នុងការអវត្តមាននេះប្រាប់ជាមុនតាមរយៈអ៊ីមែលរបស់ខ្លួនមកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥[60]។ បើទោះបីជា នួន ជា បានប្រកាសថា លទ្ធផលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខបច្ចុប្បន្ន ពុំជាប់ពាក់ព័ន្ធនឹងគាត់ក៏ដោយ[61] ក៏ពុំមានការបញ្ជាក់ច្បាស់លាស់ថាតើ ការអវត្តមានរបស់សហមេធាវីអន្តរជាតិ គឺជាផលវិបាកនៃការណែនាំជាក់លាក់របស់គាត់ដោយប្រសិទ្ធភាព ឬគ្រាន់តែ "ការពិភាក្សា" រវាងអ្នកទាំងពីរ[62]។ ការមិនបង្ហាញខ្លួនរបស់សហមេធាវីអន្តរជាតិខ្លួនឯងពុំបានបណ្តាលឱ្យកង្វះនូវការការពារក្តីស្របច្បាប់សមស្របរបស់ នួន ជា និងក្រោយមកការផ្អាកសវនាការបណ្តឹងសាទុក្ខនោះឡើយ ប៉ុន្តែ វាបានរួមចំណែកដល់ការផ្អាកនេះ រួមជាមួយនឹងការអវត្តមានរបស់សហមេធាវីជាតិផងនោះ។ ដោយសារការប្រព្រឹត្តរបស់សហមេធាវីអន្តរជាតិ ពុំបានរំលោភលើច្បាប់ជាក់លាក់ណាមួយ ឬការបង្គាប់របស់តុលាការ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សហមេធាវីអន្តរជាតិ ពុំបានជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលតុលាការ ដោយស្រមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ឬ ពាក់ព័ន្ធនឹងកំហុសវិជ្ជាជីវៈស្របតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុងឡើយ។

29. សហមេធាវីជាតិ មានវត្តមាននៅពេលចាប់ផ្តើមសវនាការលើបណ្តឹងសាទុក្ខ។ ប៉ុន្តែ កូនក្តីរបស់គាត់បានណែនាំច្បាស់លាស់ឱ្យគាត់ចាកចេញពីបន្ទប់សវនាការ ហើយគាត់ក៏បានបង្ហាញចេតនាច្បាស់លាស់គោរពតាមការណែនាំនោះដែរ[63]។ គាត់បានស្តាប់ឮអង្គជំនុំជម្រះតុលាការកំពូលធ្វើការរំឭកថា គាត់មានកាតព្វកិច្ចត្រូវនៅក្នុងបន្ទប់សវនាការ ហើយអង្គជំនុំជម្រះ បានបដិសេធអំណះអំណាងរបស់គាត់ដែលថា គាត់ត្រូវតែគោរពតាមសម្បជញ្ញៈរបស់ខ្លួន និងស្តាប់តាមការណែនាំរបស់កូនក្តីគាត់ ហើយបានចាត់ទុកការប្រព្រឹត្តរបស់គាត់ជាការធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ហើយចុងក្រោយ បានព្រមានថា ការ

[60] ការឆ្លើយតបរបស់សមេធាវីអន្តរជាតិ កថាខណ្ឌ ៣។

[61] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ ទំព័រ ១៣ (ជួរទី ១៤ ដល់ ១៥)។

[62] ប្រតិចារឹកចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ឯកសារលេខ ទំព័រ ១៣ (ជួរទី ២៤ ដល់ ២៥)។

[63] *សូមមើល*កថាខណ្ឌ ៤ ដល់ ៧ *ខាងលើ*។

រំលោភរបស់មេធាវីលើកាតព្វកិច្ចរបស់ខ្លួនដែលត្រូវតែផ្តល់ការការពារក្តីត្រឹមត្រូវតាមច្បាប់ដល់ នួន ជា នៅក្នុងបន្ទប់សវនាការ នឹងអាចឈានទៅដល់ការដាក់ទណ្ឌកម្មចំពោះការរំលោភនេះ[64]។ បើទោះបីជាមានការណែនាំ និងការព្រមានពីអង្គជំនុំជម្រះយ៉ាងណាក៏ដោយ ក៏សហមេធាវីជាតិពុំបានគោរពតាម និងត្រឡប់មកកាន់បន្ទប់សវនាការវិញ នៅពេលសវនាការបណ្តឹងសាទុក្ខបន្តក្រោយពីការសម្រាករបស់តុលាការនៅពេលព្រឹកនោះឡើយ[65]។ ការប្រព្រឹត្តរបស់គាត់ បានធ្វើឱ្យមានការផ្អាកសវនាការបណ្តឹងសាទុក្ខរហូតដល់បីខែ និងចំណាយធនធានយ៉ាងច្រើនរបស់ អ.វ.ត.ក ដែលការចំណាយនេះ អាចជៀសវាងបានទាំងស្រុង[66]។

30. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សហមេធាវីជាតិ បានអនុវត្តផ្ទុយនឹងកាតព្វកិច្ចរបស់ខ្លួនដែលត្រូវធានាបាននូវការការពារក្តីត្រឹមត្រូវតាមច្បាប់សម្រាប់កូនក្តីខ្លួនគ្រប់ពេលនៃកិច្ចដំណើរការនីតិវិធីទាំងអស់ និងបានរំលោភដោយចេតនាលើការបង្គាប់ផ្ទាល់ និងម្តងហើយម្តងទៀតរបស់តុលាការយ៉ាងច្បាស់ ដែលការរំលោភនេះបានរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខទាំងស្រុង។ លើសពីនេះទៀត សហមេធាវីជាតិ បានរំលោភលើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា ដែលតម្រូវថា មេធាវីត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនដោយ"គោរពតាម"ច្បាប់កម្ពុជា[67] និងក្រមសីលធម៌មេធាវី ដែលកំណត់ថា មេធាវី ត្រូវតែគោរពតាមវិធាននីតិវិធី និងបទបញ្ជារបស់តុលាការ និងមិនត្រូវបង្កឱ្យមានការពន្យារនីតិវិធីតុលាការណាមួយដោយមូលហេតុមិនសមហេតុផលឡើយ[68]។

31. ការដែលថា សហមេធាវីជាតិមានវត្តមានម្តងទៀតនៅក្នុងបន្ទប់សវនាការពេលរសៀល នៅពេលដែលសវនាការបណ្តឹងសាទុក្ខត្រូវបន្ត បន្ទាប់ពីអង្គជំនុំជម្រះធ្វើការពិភាក្សាសម្រេចរួចហើយនោះ ពុំបានសម្រាលដល់ការប្រព្រឹត្តដោយរំលោភបំពាននេះឡើយ។ បន្ថែមលើនេះទៀត យុទ្ធសាស្ត្រទូទៅនៃការការពារក្តីដែលមេធាវីការពារក្តី នួន ជា ប្រើប្រាស់ បានបង្ហាញពីចេតនាធ្វើពហិកាមិនចូលរួមកិច្ចដំណើរការនីតិវិធី ដូចជា ការអវត្តមានរបស់មេធាវី គឺមានន័យថា ជាការធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីតែម្តង។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងសារណាជាលាយលក្ខណ៍អក្សរក្រោយមក សហមេធាវីជាតិប្រកាន់ជំហរថា គាត់នឹងមកអង្គុយក្នុងបន្ទប់សវនាការបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ នាពេល

---

[64] *ដូចយោងខាងលើ*។

[65] *ដូចយោងខាងលើ*

[66] ដីកាកំណត់ការបរិច្ឆេទបន្តសវនាការលើបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារលេខ F30/17។

[67] ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីកម្ពុជា មាត្រា ៣៥។

[68] ក្រមសីលធម៌មេធាវី មាត្រា ៣៧ និង ៣៩។

អនាគតតាមការបង្ខំរបស់អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែ នៅតែបន្តគោរពតាមការណែនាំរបស់កូនក្តីគាត់មិនឱ្យធ្វើសារណា ឬឆ្លើយតបទៅនឹងសំណួរណាមួយឡើយ[69]។

32. ជាសរុប អង្គជំនុំជម្រះតុលាការកំពូលមានហេតុផលអាចជឿបានថា ការដែលសហមេធាវីមិនត្រឡប់មកចូលរួមសវនាការបណ្តឹងសាទុក្ខបន្ទាប់ពីការសម្រាករបស់តុលាការពេលព្រឹកនោះ គឺជាការជ្រៀតជ្រែកកិច្ចការរដ្ឋបាលតុលាការស្របតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[70]។ ទោះជាយ៉ាណាក្តី អង្គជំនុំជម្រះសម្រេចមិនយោងទៅលើវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយសារ“គោលបំណងដើម្បីទទួលបាននូវប្រសិទ្ធភាព” និងបានពិចារណាឃើញថា ការប្រព្រឹត្តបែបនេះនឹងធ្វើឱ្យចំណាយពេលវេលា និងធនធានបន្ថែមទៀត[71] នៅពេលដែលពិចារណាទៅលើទង្វើរបស់សហមេធាវីជាតិ ដែលមានលក្ខណៈឃើតយ៉ាវ បើទោះបីជាពុំទាន់ត្រូវបានចាត់ទុកថាឥតប្រយោជន៍ទាំងស្រុងនៅឡើយ ក្នុងការយកចិត្តទុកដាក់គោរពតាមការបង្គាប់របស់អង្គជំនុំជម្រះនាពេលអនាគត។

33. ទោះជាយ៉ាងក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកថា ជាការសមស្របក្នុងការយោងទៅលើទណ្ឌកម្មតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។ ដោយសារសហមេធាវីជាតិ ត្រូវបានព្រមាននៅពេលសវនាការបណ្តឹងសាទុក្ខចំពោះការរំលោភលើកាតព្វកិច្ចរបស់គាត់រួចហើយ ដូច្នេះ អង្គជំនុំជម្រះជឿបានថា ទណ្ឌកម្មដែលមានលក្ខណៈសមាមាត្រ និងចាំបាច់នៅក្នុងរឿងក្តីនេះ គឺការស្តីបន្ទោសផ្លូវការជាសាធារណៈមួយ។

34. ដោយពិចារណាបន្ថែមទៀតឃើញថា ដើម្បីផលប្រយោជន៍យុត្តិធម៌ នួន ជា ត្រូវតែបានទទួលការពារក្តីពីមេធាវីតាមការជ្រើសរើសផ្ទាល់ខ្លួន ហើយមេធាវីត្រូវគោរពតាមកិច្ចដំណើរការនីតិវិធីតាំងពីពេលចាប់ផ្តើម ដូចនេះអង្គជំនុំជម្រះតុលាការកំពូលត្រូវចេញសេចក្តីជូនដំណឹងដល់សហមេធាវីជាតិ និងអន្តរជាតិដែលតម្រូវឱ្យសហមេធាវីធ្វើការសហការជាមួយអង្គជំនុំជម្រះដើម្បីធានាបានថា នៅគ្រប់ពេលទាំងអស់ នួន ជា ត្រូវទទួលបានការការពារក្តីក្នុងអំឡុងពេលនៃសវនាការក្នុងសំណុំរឿង ០០២/០១។ ការខកខានក្នុងការធានាបានការការពារក្តីនេះ នឹងត្រូវបានចាត់ទុកថាជាការធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី។

---

[69] សារណារបស់សហមេធាវីជាតិ កថាខណ្ឌ ៩។

[70] *សូមមើល*កថាខណ្ឌ ១៩ *ខាងលើ*។

[71] សេចក្តីសម្រេចសុំឱ្យធ្វើចំណាត់ការបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ៣៩។

35. ចុងបញ្ចប់ អង្គជំនុំជម្រះតុលាការកំពូល ជូនដំណឹងដល់អង្គភាពគាំពារការការពារក្ដី នូវសេចក្ដីសម្រេចបច្ចុប្បន្នេះស្ដីអំពីមេធាវីការពារក្ដី នួន ជា ដែលលែងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខតទៅទៀត[72] រួមទាំងការខកខានរបស់សហមេធាវីអន្តរជាតិក្នុងការចូលរួមសវនាការលើបណ្ដឹងសាទុក្ខ និងស្នើឱ្យអង្គភាពគាំពារការការពារក្ដី ទទួលខុសត្រូវក្នុងការកំណត់ពីការចំណាយដែលជាបន្ទុករបស់ អ.វ.ត.ក ទៅលើសេវាកម្មផ្នែកច្បាប់របស់សហមេធាវីជាតិ និងអន្តរជាតិនៅក្នុងសំណុំរឿង ០០២/០១[73]។

---

[72] អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា មេធាវីការពារក្ដី នួន ជា ពុំបានដាក់សេចក្ដីសង្កេតដែលបានស្នើឡើងនៅក្នុងដីកាកំណត់កាលបរិច្ឆេទសវនាការបណ្ដឹងសាទុក្ខ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៥ ឯកសារលេខ F30 ទំព័រ ៤ ដល់ ៥ (នៅក្នុងកាលវិភាគព្រាង និងការកែប្រែអាចកើតមានទៅលើ"ការកំណត់ប្រភេទបទល្មើស")។ លើសពីនេះទៀត ជាការសមហេតុផល ដែលសន្មតថា ពុំមានការរៀបចំលើខ្លឹមសារលម្អិតសម្រាប់សវនាការដែលត្រូវបានធ្វើឡើង ស្របទៅតាមការសម្រេចថានឹងពុំធ្វើសារណាផ្ទាល់មាត់ ឬឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះនោះឡើយ។

[73] បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី ផ្នែកទី ៧.១។

សំណុំរឿងលេខៈ ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F30/18

## ឃ.ផ្នែកសម្រេចសេចក្តី

36. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល÷**

**កំណត់**ថា សហមេធាវីជាតិ បានប្រព្រឹត្តនូវកំហុសវិជ្ជាជីវៈ ដោយអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ក្នុងការមិនត្រឡប់មកចូលរួមសវនាការបណ្តឹងសាទុក្ខវិញ បន្ទាប់ពីការសម្រាករបស់តុលាការនៅពេលព្រឹកនោះ ហេតុនេះ គឺជាការរំលោភដោយចេតនាលើកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាបាននូវការការពារក្តីស្របច្បាប់ត្រឹមត្រូវសម្រាប់ នួន ជា និងការបង្គាប់ដោយផ្ទាល់ និងម្តងហើយម្តងទៀតយ៉ាងច្បាស់លាស់របស់អង្គជំនុំជម្រះតុលាការកំពូលឱ្យមានវត្តមាននៅក្នុងបន្ទប់សវនាការ និងដូច្នេះ អំពើនេះបានធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី,

**ស្តីបន្ទោសជាផ្លូវការ**ដល់សហមេធាវីជាតិចំពោះកំហុសវិជ្ជាជីវៈរបស់ខ្លួនតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង និងបញ្ជាក់ថា កំហុសវិជ្ជាជីវៈនេះ បានបណ្តាលឱ្យមានការផ្អាកសវនាការបណ្តឹងសាទុក្ខអស់រយៈពេលបីខែ និងបានធ្វើឱ្យ អ.វ.ត.ក ចំណាយធនធានយ៉ាងច្រើនបន្ថែមទៀត ដែលការចំណាយនេះ អាចនឹងជៀសវាងបានទាំងស្រុង,

**ជូនដំណឹង**សហមេធាវីជាតិ និងអន្តរជាតិថា ប្រសិនបើកំហុសវិជ្ជាជីវៈបែបនេះ កើតមាននាពេលអនាគតដោយសារតែការខ្វះនូវការការពារក្តីស្របច្បាប់ត្រឹមត្រូវសម្រាប់ នួន ជា ឬការរាំងស្ទះណាមួយដល់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះនេះត្រូវបានតម្រូវឱ្យធ្វើការពិចារណាដាក់ទណ្ឌកម្មធ្ងន់ធ្ងរជាងការស្តីបន្ទោសជាផ្លូវការនេះទៀត,

**ណែនាំ**មន្ត្រីទទួលបន្ទុកសំណុំរឿង ត្រូវជូនដំណឹងដល់អង្គភាពគាំពារការការពារក្តី និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានូវសេចក្តីសម្រេចបច្ចុប្បន្ននេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

គង់ ស្រ៊ឹម